## ៦.៦- សារាចរលេខ ០០១ សហវ.អលសរ ចុះថ្ងៃទី២៣ ខែកុម្ភៈ ឆ្នាំ ២០១២ ស្តីពីការអនុវត្តច្បាប់ស្តីពីលទ្ធកម្មសាធារណៈ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

លេខ: ០០១......សហវ.[illegible]

រាជធានីភ្នំពេញ ថ្ងៃទី ២១ ខែ កុម្ភៈ ឆ្នាំ ២០១២

# សារាចរណែនាំ
## ស្តីពី
## ការអនុវត្តច្បាប់ស្តីពីលទ្ធកម្មសាធារណៈ

រាជរដ្ឋាភិបាល បានប្រកាសដាក់ឱ្យអនុវត្តនូវកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ក្នុងដំណាក់កាលទី១នៅថ្ងៃទី៥ ខែធ្នូ ឆ្នាំ២០០៤ និងដំណាក់កាលទី២នៅថ្ងៃទី៣ ខែធ្នូ ឆ្នាំ២០០៨ ។ ការកែទម្រង់ក្នុងដំណាក់កាលទី១ បានដើរតួនាទីយ៉ាងសំខាន់ក្នុងការកែលម្អការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ដោយសម្រេចបាននូវភាពជឿទុកចិត្តលើថវិកា ។ ដំណាក់កាលទី២ នៃកំណែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ បច្ចុប្បន្នកំពុងផ្តោតអាទិភាពជាពិសេសទៅលើការបង្កើនគណនេយ្យភាពហិរញ្ញវត្ថុ ដែលក្នុងនោះ ការពង្រឹងកិច្ចគ្រប់គ្រងលទ្ធកម្មសាធារណៈគឺជាសមាសភាពមួយដ៏សំខាន់ ។

កន្លងមក នៅក្នុងក្របខណ្ឌនៃកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ បានធ្វើវិសហមជ្ឈការលទ្ធកម្មសាធារណៈ ដោយប្រគល់សិទ្ធិជាបន្តបន្ទាប់ជូនស្ថាប័នអនុវត្តលទ្ធកម្ម ក្នុងការអនុវត្តនិងសម្រេចលើកិច្ចលទ្ធកម្មសាធារណៈ ។ ប្រការនេះតម្រូវឱ្យផ្តោតការយកចិត្តទុកដាក់លើការពង្រឹងសមត្ថភាពនិងការទទួលខុសត្រូវរបស់ស្ថាប័នអនុវត្តលទ្ធកម្ម ។ ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុនឹងមានតួនាទីរៀបចំគោលនយោបាយលទ្ធកម្មសាធារណៈ បណ្តុះបណ្តាល សង្កេតការណ៍ និងធ្វើសវនកម្មលើកិច្ចលទ្ធកម្មដែលបានអនុវត្តរួច ។ ក្នុងស្មារតីនេះ និងស្របតាមកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ច្បាប់ស្តីពីលទ្ធកម្មសាធារណៈ ត្រូវបានប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ នស / រកម / ០១១២០០៤ ចុះថ្ងៃទី១៤ ខែមករា ឆ្នាំ២០១២ ។ ច្បាប់នេះ ត្រូវបានបង្កើតឡើងក្នុងគោលបំណងធានាឱ្យដំណើរការលទ្ធកម្មសាធារណៈសម្រាប់ការទិញ ការសាងសង់ ការជួសជុល ការផ្តល់សេវាកម្ម និងការផ្តល់សេវាទីប្រឹក្សា ប្រព្រឹត្តទៅប្រកបដោយតម្លាភាព គណនេយ្យភាព ភាពយុត្តិធម៌ ប្រសិទ្ធភាព

ផ្លូវលេខ ៩២ សង្កាត់វត្តភ្នំ ខ័ណ្ឌដូនពេញ រាជធានីភ្នំពេញ កម្ពុជា
St,92, Sangkat Wat Phnom , khan Daun Penh, Phnom Penh, CAMBODIA.
ទូរស័ព្ទ : ៨៥៥-២៣-៧២៤ ៦៦៤ ទូរសារ : ៨៥៥-២៣-៤២៧ ៧៩៨
Phone : 855-23-724 664 Fax : 855-23-427 798

គុណភាព សមភាព ការសន្សំសំចៃ និងភាពទាន់ពេលវេលា ព្រមទាំងធានាឱ្យបាននូវប្រព័ន្ធលទ្ធកម្មសាធារណៈឯកភាពមួយនៅក្នុងព្រះរាជាណាចក្រកម្ពុជា ។ ច្បាប់នេះ ក៏មានគោលបំណងរួមចំណែកក្នុងការបង្ការអំពើពុករលួយផងដែរ ។

ដើម្បីសម្រេចបាននូវគោលបំណងខាងលើ ច្បាប់ស្តីពីលទ្ធកម្មសាធារណៈ បានតម្រូវឱ្យរាជរដ្ឋាភិបាលរៀបចំនូវអនុក្រឹត្យនិងប្រកាសមួយចំនួន សម្រាប់ដាក់ឱ្យស្ថាប័នអនុវត្តលទ្ធកម្មដែលក្នុងនោះមានក្រសួង ស្ថាប័ន រាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ឃុំ សង្កាត់ សហគ្រាសសាធារណៈ គ្រឹះស្ថានសាធារណៈរដ្ឋបាល អង្គភាពស្វយ័តភាពហិរញ្ញវត្ថុដទៃទៀត និងដៃគូឯកជនសាធារណៈ អនុវត្តស្របតាមបទប្បញ្ញត្តិដែលមានចែងនៅក្នុងច្បាប់នេះ ។

ក្នុងពេលកំពុងបន្តរៀបចំលិខិតបទដ្ឋានគតិយុត្ត និងក្នុងស្មារតីនៃការពង្រឹងសមត្ថភាពនិងការទទួលខុសត្រូវរបស់ក្រសួង ស្ថាប័ន រាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ឃុំ សង្កាត់ សហគ្រាសសាធារណៈ គ្រឹះស្ថានសាធារណៈរដ្ឋបាល អង្គភាពស្វយ័តភាពហិរញ្ញវត្ថុដទៃទៀត និងដៃគូឯកជនសាធារណៈ ស្របតាមគោលការណ៍នៃកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ព្រមទាំងអនុលោមតាមមាត្រា៧៤នៃច្បាប់ស្តីពីលទ្ធកម្មសាធារណៈ ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ សូមធ្វើការណែនាំគ្រប់ស្ថាប័នអនុវត្តលទ្ធកម្មនៅក្នុងព្រះរាជាណាចក្រកម្ពុជា *ត្រូវអនុវត្តឱ្យបានត្រឹមត្រូវតាមវិធាននិងបទប្បញ្ញត្តិ វិធីសាស្ត្រនិងនីតិវិធីលទ្ធកម្មសាធារណៈ ដែលចែងក្នុងអនុក្រឹត្យលេខ១០៥ អនក្រ.បក ចុះ ថ្ងៃទី១៨ ខែតុលា ឆ្នាំ២០០៦ ស្តីពីលទ្ធកម្មសាធារណៈ និងប្រកាសលេខ៣៨១ សហវ.ប្រក ចុះថ្ងៃទី១៥ ខែមិថុនា ឆ្នាំ២០១០ ស្តីពីការដាក់ឱ្យប្រើប្រាស់សៀវភៅលទ្ធកម្មស្តីពីការអនុវត្តវិធាននិងបទប្បញ្ញត្តិស្តីពីលទ្ធកម្មសាធារណៈ និងលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធនឹងលទ្ធកម្មសាធារណៈដែលនៅជាធរមាន រហូតដល់ពេលមានលិខិតបទដ្ឋានគតិយុត្តថ្មីមកជំនួស* ។

ទន្ទឹមនឹងនេះ ស្ថាប័នអនុវត្តលទ្ធកម្មត្រូវប្រកាន់ខ្ជាប់នូវក្រមសីលធម៌លទ្ធកម្ម និងបទប្បញ្ញត្តិទាំងឡាយដែលមានចែងក្នុងច្បាប់ស្តីពីលទ្ធកម្មសាធារណៈ ពិសេសត្រង់មាត្រា៧៣ ដែលចែងថា *"បទល្មើសពុករលួយដែលមានចែងក្នុងច្បាប់នេះ និងក្នុងច្បាប់និងបទប្បញ្ញត្តិជាធរមានដទៃទៀតនៃព្រះរាជាណាចក្រកម្ពុជា ក៏ស្ថិតនៅក្រោមសមត្ថកិច្ចរបស់អង្គភាពប្រឆាំងអំពើពុករលួយដែលជាអង្គភាពតែមួយគត់ មានសមត្ថកិច្ចស៊ើបអង្កេតនិងកសាងសំណុំរឿងពុករលួយទៅតុលាការ ។ អង្គភាពនិងបុគ្គលដទៃទៀត ដែលបានដឹងពីបទល្មើសពុករលួយទាំងឡាយណាដែលមានចែងក្នុងច្បាប់នេះ និងក្នុងច្បាប់និងបទប្បញ្ញត្តិជាធរមានដទៃទៀតនៃព្រះរាជាណាចក្រកម្ពុជា ត្រូវប្ដឹងទៅអង្គភាព ឬការិយាល័យរាជធានី ខេត្ត ប្រឆាំងអំពើពុករលួយ អំពីរឿងហេតុនៃបទល្មើសទាំងនេះ"* ។

ទទួលបាននូវសារាចរណែនាំនេះ សូមសម្ដេច ឯកឧត្តម លោកជំទាវ លោក លោកស្រី ដែលជាប្រធានក្រសួង ស្ថាប័ន រាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ឃុំ សង្កាត់ សហគ្រាសសាធារណៈ គ្រឹះស្ថានសាធារណៈរដ្ឋបាល អង្គភាពស្វយ័តភាពហិរញ្ញវត្ថុដទៃទៀត និងដៃគូឯកជនសាធារណៈ យកចិត្តទុកដាក់អនុវត្តឱ្យបានម៉ឺងម៉ាត់និងមានប្រសិទ្ធភាពខ្ពស់ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

**ឧបនាយករដ្ឋមន្ត្រី**

**រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ**

**គាត ឈន់**

**ចម្លងជូន:**

- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ទីស្ដីការគណៈរដ្ឋមន្ត្រី

  "ដើម្បីជូនជ្រាប"
- គ្រប់ក្រសួង ស្ថាប័ន
- គ្រប់រាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ឃុំ សង្កាត់
- គ្រប់សហគ្រាសសាធារណៈ គ្រឹះស្ថានសាធារណៈរដ្ឋបាល អង្គភាពស្វយ័តភាពហិរញ្ញវត្ថុដទៃទៀត ដៃគូឯកជនសាធារណៈ

  "ដើម្បីអនុវត្ត"
- ឯកសារ-កាលប្បវត្តិ